UNITED NATIONS
CAMBODIA

# ការឆ្លើយតបចំពោះជំងឺកូវីដ-១៩ របស់អង្គការសហប្រជាជាតិនៅកម្ពុជា

## ឯកសារព័ត៌មាន

## ថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០២១

ជាការឆ្លើយតបចំពោះការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ អង្គការសហប្រជាជាតិផ្តល់អាទិភាព និងបន្តផ្តល់អាទិភាពដល់ការសង្គ្រោះជីវិតនិងការបញ្ឈប់ការឆ្លងរាលដាលនៃជំងឺនេះ ការកាត់បន្ថយផលប៉ះពាល់សង្គមសេដ្ឋកិច្ចលើពលរដ្ឋកម្ពុជាដែលងាយគ្រោះនិងងាយរងគ្រោះបំផុត និងការស្តារឡើងវិញឲ្យកាន់តែប្រសើរពីវិបត្តិដែលបង្កឡើងដោយសារការរាតត្បាតជាសកលនេះ។

ខ្លឹមសារខាងក្រោមផ្តល់នូវការពន្យល់ដោយសង្ខេបអំពីអ្វីដែលអង្គការសហប្រជាជាតិកំពុងធ្វើ ជាការឆ្លើយតបចំពោះការផ្ទុះឡើងនៃជំងឺកូវីដ-១៩នៅក្នុងសហគមន៍ នាពេលនេះ៖

- **ការឆ្លើយតបផ្នែកសុខភាព៖** អង្គការសុខភាពពិភពលោក កំពុងធ្វើការយ៉ាងស្អិតល្មួតជាមួយនឹងក្រសួងសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន ដើម្បីឆ្លើយតបចំពោះបញ្ហាសុខភាពចំពោះមុខ នៅក្នុងតំបន់ដែលប្រឈមនឹងហានិភ័យខ្ពស់ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា រួមទាំងក្នុងតំបន់ក្រហមផងដែរ។ អង្គការសុខភាពពិភពលោកផ្តល់ដំបូន្មានបច្ចេកទេស និងដំបូន្មានផ្នែកប្រតិបត្តិការ ដូចជា លើការតាមដានឃ្លាំមើល ដើម្បីកំណត់រកករណីឆ្លងជំងឺឲ្យបានទាន់ពេលវេលា ការវាយតម្លៃលើហានិភ័យនិងការឆ្លើយតបបែបរហ័ស ការតាមដានរកអ្នកពាក់ព័ន្ធ ការគ្រប់គ្រងគ្លីនិក ការអប់រំផ្សព្វផ្សាយអំពីហានិភ័យ និងការអនុវត្តវិធានការដែលមិនពាក់ព័ន្ធនឹងការប្រើប្រាស់ឱសថ ព្រមទាំងការផ្តល់បរិក្ខារផ្គត់ផ្គង់ចាំបាច់សំខាន់ៗ (ដូចជា ឧបករណ៍សម្រាប់វាស់កម្រិតអុកស៊ីហ្សែន ម៉ាស៊ីនផលិតអុកស៊ីហ្សែន និងឧបករណ៍ការពារខ្លួន ជាដើម)។ អង្គការសុខភាពពិភលោកក៏បន្តដល់ដំបូន្មាន និងការគាំទ្រ ដល់ការធ្វើតេស្តរកជំងឺកូវីដ-១៩ និងការអនុវត្តយុទ្ធនាការចាក់វ៉ាក់សាំងផងដែរ។ ប្រទេសកម្ពុជាឋិតនៅក្នុងចំណោមប្រទេសដំបូងៗដែលបានទទួលវ៉ាក់សាំង តាមរយៈយន្តការកូវ៉ាក់៖ កាលពីថ្ងៃទី ២ ខែ មីនា ប្រទេសនេះបានទទួលវ៉ាក់សាំង AstraZeneca ចំនួន ៣២៤ ០០០ ដូស។

- **ការផ្តល់ជំនួយស្បៀងបន្ទាន់៖** រួមគ្នាជាមួយនឹងដៃគូនៃវេទិកាឆ្លើយតបមនុស្សធម៌ អង្គការសហប្រជាជាតិកំពុងស្នើសុំការអនុញ្ញាតចូលទៅក្នុងតំបន់ក្រហម ដើម្បីផ្តល់ជំនួយស្បៀងបន្ទាន់ និងសម្ភារៈចាំបាច់ជាមូលដ្ឋានដទៃទៀតដល់ប្រជាពលរដ្ឋដែលជួបការខ្វះខាត ដោយធ្វើការសម្របសម្រួលជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ និងអង្គការសង្គមស៊ីវិលក្នុងស្រុកនានា។

- **ជំនួយសង្គម៖** អង្គការសហប្រជាជាតិបន្តផ្តល់ជំនួយបច្ចេកទេស ដើម្បីពង្រីកវិសាលភាពនៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ឆ្លើយតបចំពោះស្ថានភាពបន្ទាន់ ក៏ដូចជាការពង្រីកការអនុវត្តយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ ដើម្បី

កំណត់រកអ្នកទទួលផលថ្មីៗ ជាពិសេសអ្នកដែលពុំទាន់បានទទួលអត្ថប្រយោជន៍ដែលត្រូវផ្តល់ជូនគ្រួសារក្រីក្រនៅឡើយ។ កាលពីឆ្នាំ ២០២០ អង្គការសហប្រជាជាតិអង្គការសហប្រជាជាតិបានជួយដល់រាជរដ្ឋាភិបាល ក្នុងការពង្រីកកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភឆ្លើយតបចំពោះស្ថានភាពអាសន្ននៅកម្ពុជា ដល់ប្រជាពលរដ្ឋចំនួន ២,៥ លាននាក់។ អង្គការសហប្រជាជាតិកំពុងជំរុញជាបន្តបន្ទាប់ ឲ្យមានការបញ្ចូលអាហារចម្រុះ ដែលសម្បូរដោយអាហារូបត្ថម្ភ ទៅក្នុងកញ្ចប់ស្បៀង ដើម្បីផ្តល់ជូនមិនគិតថ្លៃដល់ប្រជាជនដែលងាយរងគ្រោះ និងអ្នកជួបការលំបាក ប្រសិនបើពួកគេពុំអាចទិញស្បៀងអាហារទាំងនេះបាន។ អង្គការសហប្រជាជាតិក៏គាំទ្រដល់ការវាយតម្លៃក្នុងទម្រង់ជាការអង្កេតតាមទូរស័ព្ទលើស្ថានភាពរបស់ប្រជាជនដែលងាយរងគ្រោះនៅក្នុងតំបន់ក្រហម តាមរយៈការសហការជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល។

- **ការបើកដំណើរការរោងចក្រកាត់ដេរឡើងវិញប្រកបដោយសុវត្ថិភាព៖** អង្គការសហប្រជាជាតិបានធ្វើការវាយតម្លៃហានិភ័យលើរោងចក្រកាត់ដេរ និងបានផ្តល់ការណែនាំអំពី ការបើកដំណើរការរោងចក្រឡើងវិញប្រកបដោយសុវត្ថិភាព៖ ការណែនាំដែលផ្តល់ជូនរោងចក្រ និងរដ្ឋាភិបាល រួមមាន អនុសាសន៍ទៅតាមកម្រិតហានិភ័យ និងបញ្ជីត្រួតពិនិត្យដែលមានបញ្ចូលសកម្មភាពនានា ដើម្បីជួយឲ្យរោងចក្រ និងកម្មករនិយោជិតឲ្យមានសុវត្ថិភាព និងកាត់បន្ថយការឆ្លងរាលដាលនៃវីរុសនេះ នៅពេលរោងចក្របើកដំណើរការឡើងវិញ និងនៅក្នុងអំឡុងពេលដែលការរាតត្បាតជាសកលកំពុងបន្តកើតឡើង។ អង្គការសហប្រជាជាតិក៏បានសហការផលិត និងផ្សព្វផ្សាយឯកសារអប់រំអំពីហានិភ័យ ដោយបានកែសម្រួលឯកសារទាំងនេះឲ្យស្របតាមស្ថានភាពរបស់រោងចក្រកាត់ដេរ និងកម្មករនិយោជិត។

អង្គការសហប្រជាជាតិនៃកម្ពុជាបានកៀរគរថវិកាចំនួនជាង ១០០ លានដុល្លារ ដើម្បីគាំទ្រដល់ការឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ និងការស្តារឡើងវិញជារួមចាប់តាំងពីឆ្នាំ ២០២០ មក។

###

សម្រាប់ព័ត៌មានបន្ថែមសុំទាក់ទងកញ្ញា កែវស្រីស្រស់ មន្ត្រីទំនាក់ទំនងនិងស្វែងរកការគាំទ្រនៃការិយាល័យប្រធានអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា តាមរយៈអ៊ីមែល sreysros.keo@un.org ។